**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា**

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី៤
# លើឯកសារអាជ្ញាប័ណ្ណរួមលេខ ១៤៤ ឯអ
# ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៦
# សម្រាប់ធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនីនៅទីប្រជុំជន ផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល សម្រាប់បន្តអាណត្តិអាជ្ញាប័ណ្ណ និងពង្រីកតំបន់ចែកចាយ

DECISION ON FOURTH REVISION
TO THE CONSOLIDATED LICENSE N$^0$ 144 LD
DATED OCTOBER 25, 2006
FOR PROVIDING ELECTRIC POWER GENERATION AND DISTRIBUTION SERVICES AT PHSAR SIEM REAP TOWN, KHUM SIEM REAP, KANDAL STEUNG DISTRICT, KANDAL PROVINCE, FOR RENEWING TERM OF LICENSE AND EXTEDING DISTRIBUTION AREA

**ថ្ងៃទី.. ខែ.. ឆ្នាំ២០០៩**

**..., 2009**

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ : -០៩ អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៤ លើឯកសារអាជ្ញាប័ណ្ណរួមលេខ ១៤៤ ឯអ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៦ សម្រាប់លោក អ៊ុក សុភាព សម្រាប់បន្តអាណត្តិអាជ្ញាប័ណ្ណ និងពង្រីកតំបន់ចែកចាយអគ្គិសនី

# DECISION ON FOURTH REVISION ON THE CONSOLIDATED LICENSE DOCUMENT Nº 144 LD DATED OCTOBER 25, 2006 FOR MR. OUK SOPHEAP FOR RENEWING TERM OF LICENSE AND EXTENDING DISTRITION AREA

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated 02/02/2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ១៤៤ឯអ ចុះនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៦

- In accordance with License Documents No. 143 LD dated October 25, 2006.

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណ និងពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក **អ៊ុក សុភាព** ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩

-In accordance with the application for renewing term of license and Extending distribution area Mr. OUK SOPHEAP dated April 22, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the consultation with concerned parties and public, made from ..., 2009 to ..., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៩

- In accordance with the decision of Electricity Authority of Cambodia's Session No. ..., dated ...., 2009.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលអាជ្ញាប័ណ្ណលេខ ១៤៤ អ ដែលបានផ្តល់ឱ្យសេវាករធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅទីប្រជុំជនផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដើម្បីផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណ :<br>-បន្តអាណត្តិអាជ្ញាប័ណ្ណរយៈពេល០៥ (ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូតដោយ អនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។<br>-ពង្រីកតំបន់ចែកចាយអគ្គិសនី បន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ។ | **Article 1**<br>To revise License N° 144 L granted to licensee to supply electric power in Phsar Siem Reap Town, Khum Siem Reap, Kandal Stung District, Kandal Province to provide the right to the licensee :<br>-To continue term of license 05 (five) years, from October 25, 2009 and may be renewed for further periods unless revoked earlier in accordance with the conditions of license.<br>- To extend the existing distribution area as show in the attached map in revised schedule1. |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី១ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ១៤៤ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents N° 144 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១៤៤ ឯអ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents N° 144 LD. |
| **ប្រការ ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃនៃឯកសារអាជ្ញាប័ណ្ណលេខ ១៤៤ ឯអ និងខ្លឹមសារ ដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល។ | **Article 4**<br>The other contents and conditions of the license document N° 144 LD with its revisions shall remain in force. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១៤៤ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ១៤៤ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document N° 144 LD has been deposited in order that the deposited license document N° 144 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី.. ខែ... ឆ្នាំ២០០៩

Phnom Penh, ....., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº ... DATED ...., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោក អ៊ុក សៀភាព ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺទីប្រជុំជនផ្សារសៀមរាប ឃុំសៀមរាប ឃុំគោកត្រប់ ឃុំព្រះពុទ្ធ និងឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ | 1. The authorized distribution Areas, where Mr. Ouk Sopheap has the right to provide the electricity distribution and supply services at Phsar Seim Reap town, Khum Seim Reap, Khum Kouk Trab, Khum Preah Putth and Khum Ampov Prey, Kandal Stung District, Kandal Province . |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 144L –Map-Ouk Sopheap- Revision4-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is termined by the boundary map 144L –Map-Ouk Sopheap- Revision4-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក អ៊ុក សុភាព មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក អ៊ុក សុភាព ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យពង្រីកឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១ នេះត្រូវធ្វើការកែសម្រួលដោយ ភ្ជាប់ជាមួយសេចក្ដីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mr. Ouk Sopheap intends to request the extension or the additional distribution areas then Mr. Ouk Sopheap shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |